**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

-ពាក្យបណ្តឹងអង្គសេចក្តី លេខ : ៣០១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦

-ឈ្មោះរឿងក្តី សំណុំរឿង រដ្ឋប្បវេណី

-សាលក្រមរដ្ឋប្បវេណីលេខ : ២៦(ង) ចុះថ្ងៃទី៣១-០៣-២០០៨

-កាលបរិច្ឆេទ ប្រកាសសាលក្រម ថ្ងៃទី៣១-០៣-២០០៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្ត សៀមរាប-ឧត្តរមានជ័យ**

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅសាលសវនាការ លេខ : ២ នៃសាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៨ ។

**បានចេញសាលក្រមចំពោះមុខ**

ដើមចោទឈ្មោះ [redacted] **ស្រីឡុន** ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ីមេផ្ទះ ទីលំនៅ។ ភូមិសំរោង ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

ចុងចំលើយឈ្មោះ [redacted] **ចុន្ទ្រា** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ ទីលំនៅ។ភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

-ខ្លឹមសារនៃសាលក្រមដែលគូភាគីទាមទារឱ្យតុលាការចេញ :

-ដើមចោទទាមទារឱ្យតុលាការចេញសាលក្រម :

១-សុំបដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ : ឧ.ជ ០០០ ៣០៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ។

២-សុំឱ្យទទួលស្គាល់ដីទំហំ ២០ម៉ែត្រ គុណ ៣០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ថ្នល់ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ព្រំដីប៊ុន តឹមហេង និងខាងលិចទល់ព្រំដីឈ្មោះ សឿម ស្ថិតនៅភូមិកំណប់ ឃុំបន្សាយរាក់ ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

៣-សុំឱ្យចុងចំលើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

-ចុងចំលើយទាមទារ ឱ្យតុលាការចេញសាលក្រម ដូចខាងក្រោម :

១-សុំបដិសេធ ការប្តឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] **ស្រីឡុន** ចោល ។

២-សុំឱ្យឈ្មោះ [redacted] **ស្រីឡុន** ទទួលស្គាល់ដីដែលមានប័ណ្ណសំគាល់សិទ្ធិ កាន់កាប់អចលនវត្ថុ លេខ : ឧ.ជ ០០០ ៣០៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ មានទំហំ ៩០០ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់ព្រំដីឈ្មោះ [redacted] សិទ្ធិ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ផ្លូវ និងខាងលិចទល់ព្រំដីឈ្មោះ ហូ សិទ្ធិ ស្ថិតនៅភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

៣-សុំឱ្យឈ្មោះ [redacted] ស្រី ឡុន ទទួលន្ទុកប្រាក់ប្រដាប់ក្តី ។

៤-សុំទាមទារសំណងជម្ងឺចិត្តពីឈ្មោះ [redacted] **ស្រីឡុន** ចំនួន ៥.០០០ដុល្លាអាមេរិក( ប្រាំពាន់ដុល្លាអាមេរិក) ។

៤៧៤



Scanned with CamScanner

## អំពីអង្គហេតុ

ដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា : ដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ : ខ.ជ ០០០៣០៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ដីនេះដើមឡើយជាដីរបស់ឈ្មោះ[redacted]ចាយ កាន់កាប់មុនឆ្នាំ២០០០ ហើយបានធ្វើពាក្យសុំដីនេះ ធ្វើសំនៅដ្ឋានដោយមានការឯកភាពពីឯកឧត្តមអភិបាលខេត្តរងទី២ ឈ្មោះ [redacted] សាម៉ន ជាគណៈកម្មាធិការដោះស្រាយដីធ្លីថ្នាក់ខេត្ត ហើយសំរេចឱ្យដីនេះទៅឈ្មោះ[redacted] ចាយ លក់ដីនេះឱ្យឈ្មោះ[redacted] សារ៉ាត់ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៤ ដែលមានទំហំដី ១៧ម៉ែត្រ គុណ ៥០ម៉ែត្រ ។ ថាដីនេះមានព្រំប្រទល់ខាងជើងជាប់ថ្នល់ ខាងត្បូងទល់ថ្នល់ ខាងកើតទល់ព្រំដីឈ្មោះ [redacted] តឹមហេង និងខាងលិចទល់ព្រំដីឈ្មោះ សឿម ។ លុះដល់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៥ ឈ្មោះ [redacted] សារ៉ាត់ បានលក់ដីនេះឱ្យខ្លួន ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៥ មានឈ្មោះ [redacted] បុត្រ និងមនុស្សមួយក្រុមមករុះរើរបង និងកាប់បំផ្លាញដំណាំរបស់ខ្លួន ដោយសំអាងថាដីនេះ ជាដីរបស់គេ ហើយបានបញ្ជាក់ថាដីរបស់គេមានប័ណ្ណកម្មសិទ្ធិកាប់កាប់អចលនវត្ថុលេខ : ០០០ ៣០៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ទៀតផង ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ឱ្យចុងចំលើយឈ្មោះ [redacted] បុត្រ បានសុំច្រានចោលការទាមទាររបស់ដើមចោទលើគ្រប់ចំណុចទាំង ៣ខាងលើនេះ ដោយសំអាងទៅលើអង្គហេតុ និងអង្គច្បាប់ ជូនភ្ជាប់មកជាមួយមានដូចរៀបរាប់ នៅក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៦ បានដាក់សំអាងជូន តុលាការពិនិត្យរួចហើយ ។

ដោយហេតុថាប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ : ០០០.៣០៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ដែលមានព្រំប្រទល់ ខាងជើងទល់ព្រំដីឈ្មោះ [redacted] សិទ្ធិ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ផ្លូវ និងខាងលិចទល់ព្រំដីឈ្មោះ[redacted]សិទ្ធិ ជាប័ណ្ណត្រឹមត្រូវរបស់សមត្ថកិច្ចជំនាញ ដើមចោទ គ្មានសិទ្ធិទាមទារដីជាកម្មសិទ្ធិស្របច្បាប់របស់[redacted]បុត្រ យកមកធ្វើ ជាកម្មសិទ្ធិរបស់ខ្លួនឡើយ ។

ចំពោះការទាមទាររបស់ដើមចោទឈ្មោះ [redacted] ស្រីឡូន ទាំងបីចំណុចខាងលើក៏គ្មានសិទ្ធិទាមទារដែរ ដោយហេតុថា នោះជាវិធានការផ្លូវច្បាប់របស់សមត្ថកិច្ច ។

មេធាវីតំណាងដោយអាណត្តិឱ្យចុងចំលើយ ប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៥.០០០ដុល្លាអាមេរិក( ប្រាំពាន់ដុល្លាអាមេរិក) ពីឈ្មោះ [redacted] ស្រីឡូន និងឱ្យឈ្មោះ [redacted] ស្រីឡូន ទទួលបន្ទុកពន្ធប្រាក់ប្រដាប់ក្តីទាំងអស់ ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទអះអាងថា : ដីទំនាស់ខាងលើដែលបានរៀបរាប់ ក្នុងសេចក្តីថ្លែងការណ៍នោះមេធាវីតំណាងដោយអាណត្តិឱ្យ ចុងចំលើយលើកឡើងថា ឆ្លងតាមនីតិវិធីដោះស្រាយដីទំនាស់នេះមានអង្គហេតុប្រហាក់ប្រហែលគ្នា ខ្លួនគ្រាន់តែសុំបញ្ជាក់ប្រវត្តិខ្លះ១ថា កូនក្តីរបស់ខ្លួនបានទិញដីបន្តពីអ្នកដែលកាន់កាប់យូរមកហើយ១ សិទ្ធិនៃការកាន់កាប់របស់គាត់គឺគាត់ក្លាយជាម្ចាស់កម្មសិទ្ធិ ដែលគាត់ទិញលក់ដោយមានលិខិតបញ្ជាក់ត្រឹមត្រូវ ទើបកូនក្តីខ្លួនទិញតាមផ្លូវច្បាប់ ។ ឆ្លងតាមឯកសារទិញលក់ និងឆ្លងតាមម្ចាស់ដើមត្រឹមត្រូវនោះខ្លួនសំណូមពរសូមឱ្យលោកចៅក្រមផ្តល់សិទ្ធិឱ្យកូនក្តីខ្លួនផងចុះ ដោយការកាន់កាប់របសកូនក្តីខ្លួនមានសិទ្ធិគ្រប់គ្រាន់ហើយការទិញ

២២៥

លក់នេះមានលក្ខណៈត្រឹមត្រូវពុំមានអ្វីខុសច្បាប់ទេ ហើយការកាន់កាប់គឺកូនក្តីខ្លួនកាន់កាប់តាំងពីមុនចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះមកម្ល៉េះ។ នៅពេលនេះខ្លួនបដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុខាងលើនេះទាំងស្រុង និងសុំឱ្យលោក ចៅក្រម ផ្តល់ដីនេះឱ្យកូនក្តីខ្លួនគ្រប់គ្រងបន្តទៀត។

**សាក្សី :**

១-ឈ្មោះ [redacted] **សាខន** អភិបាលស្រុកសំរោង បានធ្វើសេចក្តីថ្លែងការណ៍ថា : ដីនេះក្រោយពីខេត្តបង្កើតនៅឆ្នាំ ១៩៩៩ គឺដីនេះជាដីប្រភេទដីធ្វើស្រែ និងដាំដំណាំចម្ការ ថាដីនេះកន្លងមកពុំមានអ្នកណាធ្វើស្រែ ឬដាំដំណាំទេ ព្រោះដីនេះមានមីន និងទុកចន្លោះទំនេរចោល។ ដីនេះរដ្ឋបានទុកជាតំបន់រដ្ឋបាល។ ថាតំបន់រដ្ឋបាលនេះគឺប្រជាជនគាត់ដឹង ព្រោះកន្លងមកគាត់នាំគ្នារស់នៅជាបណ្តោះអាសន្ន មិនអាចឱ្យអ្នកណាម្នាក់ធ្វើជាកម្មសិទ្ធិបានទេ ហើយពេលដែលរដ្ឋយកដីនេះធ្វើជាតំបន់រដ្ឋបាល គឺខេត្តបានដោះដូររួចហើយដែរ។

២-ឈ្មោះ [redacted] **វិត** ជាជំទប់ទី២. បានធ្វើសេចក្តីថ្លែងការណ៍ថា : ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ តំបន់នេះគឺប្រជាជនភូមិកំណប់ មករស់នៅភូមិបន្សាយរាក់ ដូច្នេះការធ្វើបញ្ជីគ្រួសារមិនទាន់បានកំណត់ថាជាភូមិណាទេ។

៣-ឈ្មោះ [redacted] **យូ** បានធ្វើសេចក្តីថ្លែងការណ៍ថា : ដីនេះជាដីភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ថាប្រវត្តិដីនេះដូចលោកមេធាវីលើកឡើងមែន ហើយពេលដែលភូមិបាលប្រគល់ដីនេះឱ្យចុងចំលើយគឺដីនេះស្ថិតនៅក្នុងភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ។

៤-ឈ្មោះ [redacted] **គេរិន** ជាប្រធានការិយាល័យសុរិយោដីភូមិបាលខេត្តបានធ្វើសេចក្តីថ្លែងការណ៍ថា ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ ចុងចំលើយបានធ្វើត្រឹមត្រូវតាមច្បាប់ហើយ ទើបមន្ទីរសុរិយោដីខេត្តបានចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុឱ្យទៅចុងចំលើយ។ រាល់ឯកសារសុរិយោដីបើមិនបានបញ្ជាក់ពីមេឃុំ និងរដ្ឋអំណាចមកទេនោះ មន្ទីរខ្លួនមិនអាចចេញប័ណ្ណឱ្យបានទេ ហើយការចេញប័ណ្ណនេះគឺអគ្គនាយកសុរិយោដីជាអ្នកចេញ។

៥-ឈ្មោះ [redacted] **សាវុធ** ប្រធានការិយាល័យភូមិបាលបានធ្វើសេចក្តីថ្លែងការណ៍ថា : ការកាន់កាប់នេះពាក្យស្នើរសុំកាន់កាប់ដី និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ មានលក្ខណៈខុសគ្នាគឺប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ មានសំអាងច្បាស់លាស់ ហើយមានសិទ្ធិគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ឯពាក្យស្នើសុំកាន់កាប់ដីធ្លីគឺគ្រាន់តែជាពាក្យស្នើសុំប៉ុណ្ណោះ ឯរដ្ឋអំណាចមិនទាន់ទទួលស្គាល់សិទ្ធិគ្រប់គ្រងទេគឺប្រៀបដូចជាពាក្យសុំប្រឡងប៉ុណ្ណោះមិនទាន់ដឹងថាជាប់ឬធ្លាក់ឡើយ។ ក្រុមវាស់វែងបែងចែកដីឡូត៍ឱ្យចុងចំលើយមួយឡូត៍ គ្រប់ៗគ្នាដោយមានចំណារពីអភិបាលរងខេត្ត។ ចំពោះការស្នើសុំពីប្រជាពលរដ្ឋមកអភិបាលខេត្តនោះខេត្តពុំបានសម្រេចប្រគល់ដីឱ្យទេ។

៦-ឈ្មោះ [redacted] **រួន** បានធ្វើសេចក្តីថ្លែងការណ៍ថា : កាលពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៩៣ ដីនេះដំបូងឡើយជាដីភូមិឈូក ដីទំនាស់នេះខ្លួនកំណត់ថាជាដីភូមិកំណប់ ព្រោះបច្ចុប្បន្នប្រជាជនភូមិឈូក , ភូមិកំណប់ ភូមិបន្សាយរាក់ មករស់នៅជុំគ្នាមិនដឹងថាគេកំណត់ភូមិនេះជាភូមិអ្វីទេ។

អំពីចំណុចវិវាទនៃរឿងក្តីនេះមាន

**ការសំអាងហេតុ**

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងសេចក្តីថ្លែងការរបស់មេធាវីតំណាងដោយអាណត្តិ ឱ្យចុងចំលើយ បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមកឃើញថា :

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យ របស់ចុងចំលើយបានច្រានចោល អង្គហេតុ និងការទាមទាររបស់មេធាវីតំណាងដោយអាណត្តិ របស់ដើមចោទលើគ្រប់ចំណុច ហើយមាន ភស្តុតាង សំអាងដែលអាចយកមកពិចារណាបាន ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យ ដើមចោទ បានសុំឱ្យតុលាការ ចេញសាលក្រមសំរេច ដូចការទាមទារទាំង ៣ចំណុចខាងលើ ក៏ប៉ុន្តែអំណះអំណាងដូចមានសេចក្តីថ្លែងការណ៍របស់តំណាងឱ្យដើមចោទ គ្មានអ្វីជាបន្ទាល់គួរឱ្យតុលាការជឿបានឡើយ ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ ចុងចំលើយ បានធ្វើសេចក្តីថ្លែងការណ៍ ដាក់ជូនតុលាការពិនិត្យរួចហើយ នោះមានភស្តុតាងជាក់លាក់សមស្របតាមច្បាប់ គួតុលាការពិចារណាលើបញ្ហានេះបាន ។

-ឆ្លងតាមអង្គជំនុំជំរះក្តីនាពេលនេះឃើញថា : តាមលោកមេធាវីតំណាងដោយអាណត្តិរបស់ចុងចំលើយ បានលើកលើងអំពីប្រវត្តិដីមានទំនាស់ ជាដីរបស់ចុងចំលើយ ដោយមានសំអាងច្បាស់លាស់ ពីប្រភពដើមនៃដីនេះ ដោយមានភស្តុតាងជាឯកសារ ដែលអាចឱ្យតុលាការជឿបានដូចជា :

-មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ : ឧ.ជ ០០០.៣០៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ។

-កាវ៉ាយត៍លៃប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ របស់មន្ទីរៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តឧត្តរមានជ័យ ។

-លិខិតលេខ : ១៣១៤ ឧ.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៣ របស់អភិបាលរងខេត្តឧត្តរមានជ័យ ដែលបានផ្តល់ដីមួយប្លង់ទំហំ ៣០ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ឱ្យឈ្មោះ អ៊ុំ បុត្រ ដើម្បីសង់លំនៅដ្ឋាន ។

**សេចក្តីសំរេចពួច**

១-ច្រានចោលការទាមទាររបស់ឈ្មោះ[redacted] **ស្រីឡន** ជាដើមចោទទាំងស្រុង ។

២-ទទួលស្គាល់ការទាមទាររបស់ចុងចំលើយ ដែលទាមទារឱ្យទទួលស្គាល់ដីទំហំ ៩០០ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ : ឧ.ជ ០០០.៣២៦ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ដែលមានព្រំប្រទល់ ខាងជើងទល់ព្រំដីឈ្មោះ [redacted] សិទ្ធិ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ផ្លូវ និងខាងលិចទល់ព្រំដីឈ្មោះ [redacted] សិទ្ធិ ស្ថិតនៅ ភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ជារបស[redacted] បុត្រ ជាកម្មសិទ្ធិស្របច្បាប់របស់ ឈ្មោះ[redacted] បុត្រ ។



Scanned with CamScanner

៣-ឱ្យដើមចោទឈ្មោះ [redacted] **ស្រីឡូន** បង់ជម្ងឺចិត្តចំនួន ៥០ម៉ឺនរៀល (ហាសិបម៉ឺនរៀល) ឱ្យទៅឈ្មោះ [redacted] បុត្រ។ សុំលើសពីនេះលើកចោល។

៤-ឱ្យឈ្មោះ [redacted] **ស្រីឡូន** ទទួលបន្ទុកប្រាក់ប្រដាប់ក្តីទាំងអស់។

៥-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

សាមីខ្លួនមានសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិត សាលក្រមនេះ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]



Scanned with CamScanner